## II ‒ ពិធីចងសំពោង និង ពិធីកាត់សក់បង្កក់ឆ្នប :

ប្រភេទតន្ត្រីទាំង ១២ ដែលយើងបានរៀបរាប់ខាងលើមានវិសាលភាពទូលំទូលាយ ដោយបទភ្លេង ដោយឧបករណ៍ ឬ ដោយការកំដរពិធី ។ ប៉ុន្តែយើងនៅមានប្រភេទតន្ត្រីតូចៗជាច្រើនទៀត សំរាប់កំដរតែពិធីមួយៗដាច់ដោយឡែក ដូចជាប្រភេទតន្ត្រីសំរាប់ការទាក់ជីវី របាំត្រុដិ និង ត្រុដិនាងម៉េវជាដើម ។

អត្ថន័យខាងដើមក៏បានបង្ហាញ និង សរបញ្ជាក់ឲ្យយើងបានដឹងថា តន្ត្រីមានតួនាទីយ៉ាងសំខាន់ និង ជំពេងណាស់ក្នុងជីវិតរស់នៅរបស់ខ្មែរ ។ តន្ត្រីបានកំដរជីវិតរបស់គេគ្រប់កាល ទោះជីវភាពពិសេសក៏ដូចជាការរស់នៅប្រចាំថ្ងៃ ។ ទោះបីការសប្បាយ ឬ ការកើតទុក្ខ ក៏ត្រូវមានតន្ត្រីកំដរ នេះគឺជាបុគ្គលិកលក្ខណៈពិសេសរបស់ខ្មែរ ។

តទៅនេះយើងនឹងសូបលើកនូវតន្ត្រីប្លែកៗខ្លះទៀត ដែលទាក់ទិន និង ទារកខ្មែរ ពេលដែលចាប់បដិសន្ធិក្នុងផ្ទៃមាតារហូតដល់យុវវ័យ ហើយពីយុវវ័យដល់ថ្ងៃស្លាប់ ។

### ក ‒ ពិធីចងសំពោង

ស្ត្រីជាមាតា នៅពេលសង្កេតយល់ឃើញថាគ្រប់អាការៈរបស់ខ្លួនច្បាស់ជាមានគភ៌ បានប្រហែល៣ខែហើយ នាងតែងប្រាប់ដល់គ្រួសារ ពិសេសស្វាមីរបស់នាង ។ ក្នុងឱកាសនោះគេត្រូវរៀបពិធីមួយហៅថា « **ពិធីចងសំពោង** » ។ គេរៀបពិធីនេះដើម្បីបួងសួងសំណូមពរនិងឧទ្ទិសដល់វត្ថុស័ក្តិសិទ្ធិ មេត្តា



បណ្តុះដៃជើងមុខមាត់របស់បុត្រ នៅពេលប្រសូត្រចាកផ្ទៃកុំឲ្យវិកលវិការ ឬ អង្គត់ ។ ម្យ៉ាងទៀត សូមឲ្យជួយចងភ្ជាប់ព្រលឹងវិញ្ញាណនិងគ្រប់អាការៈទាំងអស់របស់បុត្រ ដែលនៅក្នុងផ្ទៃនោះ កុំឲ្យរបូតរបេះពីគ្នាបានឡើយ ។

លក្ខណៈដ៏ពិសេសនៃពិធីចងសំពោង គឺភាពសំយោគរវាងជំនឿដូនតាខ្មែរ និង សាសនាក្លិង្គ មានព្រះពុទ្ធសាសនាមហាយាន និង ព្រហ្មញ្ញសាសនា ដូចជាការអធិប្បាយខាងក្រោមនេះ ជាសក្ខីភាពស្រាប់ ។

ន័យនៃពាក្យសំពោង គឺគេធ្វើការប្រៀបធៀបទៅនឹងដើមសំពោង ។ ធម្មជាតិបានបង្កើតរុក្ខជាតិសំពោង ឲ្យមានស្លឹកនិងទងច្រើន ដែលបង្ខាំជាប់គ្នានឹងទងធំមួយ ហើយមិនងាយរបេះចេញពីគ្នាបានឡើយ ។ ចំពោះផ្កាក៏មានសភាពកញ្ចុំៗយ៉ាងល្អប្លែក មិនងាយរបេះចេញពីគ្នារហូតដល់ប្រែក្លាយទៅជាផ្លែយ៉ាងច្រើន ជាប់គ្នាជាចង្កោមៗ មិនងាយរបេះតាមកំលាំងខ្យល់ឡើយ ។ វានឹងរបេះបែកចេញពីគ្នាព្រមទាំងបែកធ្លាយចេញគ្រាប់ ចំពោះផ្លែនិមួយៗផងនោះ គឺនៅពេលវាទុំតាមក្រឹត្យក្រមរបស់ច្បាប់ធម្មជាតិ ។

ចំពោះពិធីនេះ គេមិនរៀបចំធំដុំទេ គឺគេអញ្ជើញតែញាតិមិត្តជិតដិត ពិសេសចាស់ទុំក្នុងភូមិ ។ ជាដំបូងអាចារ្យចាប់សូត្រធម៌នមស្ការថ្វាយបង្គំព្រះជាមួយអ្នកចូលរួម ចំពោះមុខតុអាសនៈដែលគេបានរៀប ។ នៅលើតុនោះ មានព្រះពុទ្ធបដិមា និងគ្រឿងសក្ការបូជា មានស្លាធម៌មួយគូ ផ្តិលទឹកមួយដែលមានបង់ផ្កាម្លិះផ្កាឈូក ឬ បាញ់ទឹកអប់ផង ស្លា៥ បារី៥ ផ្កាមួយថូ និង

ទៀនធូបអុជថ្វាយគុណព្រះរតន ត្រ័យនិងវត្ថុស័ក្តិសិទ្ធិ ។ បន្ទាប់មកអាចារ្យរំពាវនាវប្រកាសអញ្ជើញទេវតា ព្រះឥន្ទ ព្រះព្រហ្ម អ្នកមានបុណ្យបារមីមានមហិទ្ធិឫទ្ធិ សូមមកជួយឲ្យពរជ័យដល់ជីវិតដែលមកចាប់ផ្ទៃ សូមឲ្យបានសុខសប្បាយ ។ ពិសេសសំណូមពរដល់គ្រូបាធ្យាយ និង ម្តាយដើមដែលបានមកនៅជួយថែរក្សាជីវិតថ្មីនេះ សូមជួយទាំងម្តាយឪពុកនៃអ្នកឲ្យកំណើតនេះផង គឺឲ្យសុខសប្បាយហើយឲ្យរកស៊ីមានបានត្រជាក់ត្រជុំទៀត ដើម្បីកូនក្នុងផ្ទៃបានរស់នៅលើគំនរមាសប្រាក់ទ្រព្យសម្បត្តិ ។ បន្ទាប់មកវង់ភ្លេងប្រពៃណីចាប់ប្រគុំបទហោមរោងអញ្ជើញគ្រូ អញ្ជើញរស់លោកអ្នកបរមបុណ្យបារមី . . . ។ លោកអាចារ្យចាប់យកផ្តិលទឹកដែលបានដាក់លើតុសក្ការៈមករលាស់ទឹកមន្តប្រោះព្រំទៅលើនារីជាម្តាយដោយយកធម៌ « **លើករាសី** » មកសូត្រជាបន្តបន្ទាប់ ។

ជាបន្តគេលើកម្ហូបអាហារ មានទឹក បង្អែម ចំអាប ផ្លែឈើមកដាក់លើកន្ទេលមុខអាសនៈ ហើយអុជទៀនធូបនៅលើចានកែវដោយសូមអញ្ជើញអ្នកមានអំណាចទាំងនោះ មកពិសាភោជនាហារ ។ អ្នកភ្លេងលេងបទកងសោយ គឺជាបទសំរាប់ឲ្យឥយក្នុងឱកាសសេពសោយ ឬ លេងបទចំបក់រោយ ដែលមានន័យថាត្រូវតែសំបូរពោរពាសនូវផល្លានុផលដូចដើមចំបក់ ដែលបរិបូណ៌ទៅដោយផ្លែធ្លាក់ដេរដាសពាសពេញដី ។ ពេលកំពុងលេងបទនេះ គេបាចអង្ករ លុយ ជាបណ្តើរៗ ដោយបាញ់ទឹកអប់ឲ្យក្រអូបឈ្ងុយឈ្ងប់ផង សំរាប់ឲ្យពពួកខ្មោចរាយរងរេពលដែលបានមកហែហម ទេវតា ព្រះឥន្ទ្រ ព្រះព្រហ្ម . . . ។ ចប់ពិធីសេពសោយនេះ



គេលេងបទអុំទូក ដើម្បីជូនដំណើររស់លោកវិលត្រឡប់វិញ ។ ពិធីនេះសន្មតចប់ត្រឹមនេះដែរ ។

ពិធីចងសំរោងនេះ រាស្ត្រសាមញ្ញមិនសូវរៀបចំទេ ។ ប៉ុន្តែចំពោះវង្សក្សត្រ តែងរៀបចំជាទំនៀមខានមិនបាន ឯភ្លេងលេងកំដរ គឺវង់តន្ត្រីពិណពាទ្យ ។ គេលេងបទសាធុការ នៅពេលបួងសួង ពេលថ្វាយក្រយាសោយលេងបទសែនលាវ និង លេងបទដំណើរចុះជាកិច្ចបញ្ចប់កម្មវិធី ។



ផ្លែសំរោង

### ខ – ពិធីកាត់សក់បង្កក់ឆ្មប :

ដូចពិធីចងសំរោង ពិធីកាត់សក់បង្កក់ឆ្មប ជាទំនៀមទំលាប់របស់ខ្មែរសុទ្ធសាធ ដែលមានមកពីបុរាណកាល ។ ចំណុចខ្លះដែលទាក់ទងនឹងព្រះពុទ្ធសាសនា គ្រាន់តែជាទំនៀមទំលាប់បរទេសដែលផ្សាភ្ជាប់ទៅលើគ្រឹះជំនឿចាស់តែប៉ុណ្ណោះ ។

នៅពេលទារកកើតបាន ៧ថ្ងៃ ១៥ថ្ងៃ ឬ ១ខែ គឺយោលតាមការសន្មតក្នុងគ្រួសារ ប្រជារាស្ត្រខ្មែរមានរៀបពិធីមួយហៅថា « កាត់សក់បង្កក់ឆ្មប » ។ តាមពួកព្រាហ្មណ៍គេហៅថា « នាមគ្គរណាបង្គល » គឺជាបង្គលទី១ ឬជាមង្គលដើមដំបូងប្រចាំជីវិត។ គេរៀបចំឡើង ដើម្បីដាក់នាមឲ្យទារកដែលទើបកើត ដោយឆ្លងការគិតគូរដ៏ម៉ត់ចត់តាមក្បួនតម្រា ព្រោះគេមានជំនឿថា ការដាក់ឈ្មោះនេះ គឺជាការកំនត់វាសនាអនាគតរបស់មនុស្សគ្រប់រូបដែរ ។ ប្រសិនបើដាក់ខុសក្នុងក្បួន អ្នកដែលមានវាសនាខ្ពស់អាចចុះអន់ថយបាន ។ ទន្ទឹមនឹងការដាក់នាមឲ្យទារក ប្រជារាស្ត្រខ្មែរមានរៀបចំពិធីបង្កក់ឲ្យពរជ័យ និង ការប្រគល់ជូនទារកឲ្យមកឪពុកម្ដាយរបស់ឆ្មប នូវបុត្រដែលគាត់បានបង្កើតផ្ទាល់ដៃ ។ ការរៀបចំពិធីនេះ មិនមានអាចារ្យទេ គឺមានតែញាតិមិត្តជិតដិត ជីដូនជីតា ពិសេសឪពុកបង្កើតរបស់ទារក ដែលត្រូវចាត់ចែងរៀបរណ្ដាប់ជាសគុណដល់ឆ្មប ព្រោះគេមានជំនឿថាភារកិច្ចរបស់ឆ្មបនៅពេលបង្កើតទារកនេះ ជាអំពើលំបាកឿយហត់ មិនខ្ពើមរអើមចំពោះឈាម. . . ។ ម្ដាយ និង ទារកមានជីវិតរស់នៅតទៅទៀតបាន គឺអាស្រ័យដោយឆ្មប ។ ដូច្នេះការសុំខមាទោស គឺជា



ការចាំបាច់របស់ម្ដាយ ដែលទន្ទឹមនោះបុរសជាប្ដី ក៏ត្រូវចូលរួមសុំខមាទោសដែរ ។ ប្រសិនបើពុំមានពិធីនេះទេ ម្ដាយនឹងទទួលបាបកម្មទៅអនាគតជាតិ ដោយប្រការផ្សេងៗមិនខាន ។

រណ្ដាប់ដែលត្រូវរៀបពលីការជូនឆ្មបមាន ៖

- ស្រូវ ១កញ្ចាំង
- ជម ៤
- ម្លូ (*ច្រើនត្របក*) និងស្លា (*ទាំងស្មែង*)
- មាន់ស្ងោរ ១ ក្បាលជ្រូក ១
- ស្រា ១កំប៉ុក*
- សំពត់ស ១អាវ (*២ម៉ែត្រ*)
- ទៀនធូប និង ប្រាក់កាស (*តាមធនធាន*)

ពេលរៀបរណ្ដាប់ស្រេចហើយ គេយកទារកមកដេកលើម៉ក់នៅចំកណ្ដាលផ្ទះ ក្បាលបែរទៅទិសខាងកើត ឯចុងជើងគេរៀបថាសម្លូប និង បង្អែម ព្រមអមដោយសំលៀកបំពាក់ឆ្វេងស្ដាំ និង គ្រឿងអលង្ការផ្សេងៗផង ។

ឆ្មបចាប់ផ្ដើមរុជទៀនធូប អញ្ជើញគ្រូដែលថែរក្សាគាត់ ។ ឯឪពុកទារករុជទៀនធូបដោយអញ្ជើញគ្រូបាធ្យាយ និង ម្ដាយដើមដែលត្រូវមកតាមបង្ហាត់បង្រៀន និង មើលថែរក្សាទារក ព្រមទាំងអញ្ជើញវត្ថុស័ក្តិសិទ្ធិ មានឫទ្ធិចេស្ដាមកសេពសោយអាហារ ។

ភ្លេងប្រពៃណីខ្មែរចាប់លេងបទហោមរោង ដែលជាបទអញ្ជើញគ្រូ បន្ទាប់មកលេងបទកងសោយ ។ ក្នុងឱកាសជាមួយ

---

* ដបដែលមានរាងខ្លីមូលកំប៉ុកៗ ។

គ្នានោះដែរ ឆ្មបយកទឹកខ្មៅចិនមកលាយជាមួយទឹកដោះម្តាយ ឬស្រាទៅលាបចិញ្ចើម និង សក់ទារក ដែលគេហៅថា « ការបើកភ្នែក » ។ បន្ទាប់មក ឆ្មបកាត់សក់ព្រៃនៅលើបង្ហើយបន្តិចដាក់ក្នុងកូនកន្ទោងមួយ ដែលគេបានដាក់បង្អែមចំអាបរួចហើយៗ ប្រូចទឹក និង ស្រាបន្តិចផង រួចគេយកកន្ទោងនោះ ចេញទៅដាក់ក្រៅផ្ទះសំរាប់ថ្វាយព្រះភូមិ ម្ចាស់ទឹក ម្ចាស់ដី ។

បន្តមកទៀតចូលដល់ពិធីជញ្ជាត់ព្រលឹង ឬ ហៅព្រលឹងរបស់ទារក ។ ដំបូងគេយកចិញ្ចៀនមាស១វង់ ចងអំបោះឆៅ ហើយសំបូងសង្រូងហៅព្រលឹងតូចធំ ៗ ដែលនៅក្នុងព្រៃមិនទាន់បានមកឲ្យមកសណ្ឋិតថែរក្សាទារក ។ ភ្លេងលេងកំដរនូវបទជញ្ជាត់ព្រលឹង ។ បន្ទាប់គេយកចិញ្ចៀនដែលជាតំណាងព្រលឹងនោះ មកចងដៃទារកម្ខាង ឯដៃម្ខាងទៀតគេចងអំបោះឆៅ និងឲ្យពរគ្រប់ៗគ្នាដោយភ្ជាប់ជាមាស ឬ ប្រាក់កាសខ្លះ ដែលគេហៅថាភ្ជាប់ព្រលឹង ។ ជាបន្ត គេរង្គុយព័ទ្ធជុំវិញទារកដើម្បីបង្វិលពពិល។ ក្នុងពេលជាមួយគ្នានោះដែរ អ្នកភ្លេងត្រូវលេងបទសុំបុណ្យ ឬ បទឥសីឲ្យពរ ។ ឯសេចក្តីនៃទំនុកនោះ គឺសំណូមពរសុំបុណ្យ និង យសសក្តិ សេចក្តីសុខ និង សេចក្តីចំរើនដល់ទារក និង ម្តាយដើម្បីថែរក្សាកូន ។

ក្រុមគ្រួសារញាតិមិត្ត ក៏បានពិភាក្សាគ្នាដាក់ឈ្មោះឲ្យទារក។ ឈ្មោះដែលគេយកមកឲ្យជ្រើសរើសនោះ យោលតាមការពិចារណាពីឪពុកម្តាយ ជីដូន ជីតា ឆ្មប ឬ គេសុំពីព្រះសង្ឃ ហើយគេក៏ឯកភាពសំរេចយកឈ្មោះណាមួយ ដែលគេពេញចិត្តថាសមជាង



គេ ។ ទារកដែលនៅដេកលើម៉ក់នោះ ត្រូវបានគេប្រោះម្សៅទឹករប់ និង បិទពន្លៃដែលគេបានបុកម៉ត់ ហើយពួកប៉ុនមេដៃបិទលើបង្ហើយ ដែលត្រូវផ្លាស់ជារៀងរហូតដល់មួយឆ្នាំក៏មាន ព្រោះគេយល់ថាការបិទពន្លៃនេះ រពចនាំឲ្យទារកមានសុខភាពល្អ មិនងាយផ្លាស់សាយហៀរសំបោរ ។

ជាបញ្ចប់គេលេងបទរុំទូក ដើម្បីជូនដំណើររបស់លោកត្រឡប់វិលវិញ ។ នៅពេលចប់ពិធី ឪពុកទារក និង ក្រុមគ្រួសារត្រូវជួយជញ្ជូនគ្រឿងរណ្តាប់ដែលបានរៀបរាប់ជូនឆ្មបខាងលើនោះទៅដាក់ជូនដល់ផ្ទះឆ្មប ដើម្បីឆ្មបដាក់ថ្វាយគ្រូដែលជាអ្នកថែរក្សាគាត់ក្នុងជំនាញបង្កើតទារក ឲ្យកាន់តែកើនសមត្ថភាព និង ផ្តល់សេចក្តីសុខក្នុងមុខរបរនេះ និង ឲ្យកាន់តែទទួលបានជោគជ័យជានិច្ច ។

សម័យកាលឥឡូវនេះ បន្ទាប់ពីបានសំរាលបុត្រនៅមន្ទីរពេទ្យតាមរបៀបវេជ្ជសាស្ត្រកន្លងមកបាន១ខែ គេមានរៀបចំពិធីបង្កក់ដែរ តែគេគ្រាន់តែអញ្ជើញញាតិមិត្តមកពិសា ភោជនាហារកំសាន្ត ហើយក៏បានជូនពរដល់ទារក ដោយចងដៃជាមាស ប្រាក់កាស ឬ សំលៀកបំពាក់ ប្រដាប់ប្រដាដល់ទារក ដើម្បីភ្ជាប់ព្រលឹងតែប៉ុណ្ណោះ ។



ពិធីបង្កក់ឆ្អប

### III ~ តន្ត្រី និង ទំនុក

ក្នុងវិស័យតន្ត្រីនិងជីវិតរបស់ខ្មែរ គប្បីបញ្ចូលក្នុងប្រភេទតន្ត្រីនូវបទចម្រៀងបំពេ កូន ថ្វីត្បិតតែគ្មានឧបករណ៍ភ្លេងប្រគុំក៏ដោយ ។ ចំពោះយើងចម្រៀងបំពេ កូនទាំងអស់នោះ ជាតន្ត្រីមួយប្រភេទដែលប្រកបដោយអត្ថន័យដ៏ខ្ពង់ខ្ពស់បំផុត ព្រោះវាជាការបបោសអង្អែល ការអង្វរករ សេចក្ដីស្នេហារបស់មាតា និងគុណាបំណាច់ទៅលើកូនរបស់ខ្លួនដែលស្រឡាញ់ស្មើនិងជីវិត ។

ក្នុងវ័យទារកនិងកុមារតូចៗ បានដំណើរការរស់នៅទៅមុខជារៀងរាល់ថ្ងៃ ដោយមិនបានរៀបចំពិធីអ្វីទៀតទេ ។ ប៉ុន្តែជីវិតរស់នៅជារៀងរាល់ថ្ងៃ ទារកនិងកុមារតូចៗ តែងបានទទួលការថ្នាក់ថ្នមបបោសអង្អែល និង ទំនុកបំពេ ពីអ្នកម្ដាយ បងស្រី ឬ ជីដូនដើម្បីឲ្យនាងសំរាកលង់លក់ប្រកបដោយមនោសញ្ចេតនាត្រជាក់ចិត្តជានិច្ច ។ ទំនុកបទបំពេ នោះ ច្រើនលើកឡើងភ្លាមៗតាមការឆើតឃើញជាក់ស្ដែង សំរបតាមហេតុការណ៍ គឺលួងទារកឲ្យបានស្ងប់ចិត្តលង់លក់ទៅ ។

ទំនុកនោះមានជាអាទិ៍គឺ ៖

- និអូនហ្អើយ អូនគេងទៅ ម៉ែយើងមិននៅ
  គាត់ទៀយណាស់ ព្រលឹមទល់ព្រលប់ រលាំងរលះ
  ម៉ែយើងទៀយណាស់ ដកហើយស្ទូងផង
  ហា អឺអើយ ម៉ែយើងទៀយណាស់ ដកហើយស្ទូងផង។
- អើយទាំងជើង និទាំងដៃ ពុំដែលសំចៃ

ទាំងមាត់រំពង  ទំធ្វើការងារ  ដើម្បីឲ្យកូនៗ
ដកផងស្ងួងផង  បង្អើលចាបពួក
ហារីអើយ  ដកផងស្ងួងផង  បង្អើលឱចាបពួក ។

ទន្ទឹមនឹងនោះ ក៏មានទំនុកផ្សេងៗទៀត សំរាប់សំរួលឥរិយាបថរបស់ទារកដែរ ដូចជា ៖

**ក ~ នៅពេលទារកកើតចិត្តមួហ្មង :**

គេមានចិត្តមួហ្មងដោយសំរាកមិនទាន់បានឆ្អែតស្កប់ស្កល់ឬ អារម្មណ៍មិនជ្រះស្រឡះចង់យំ អ្នកមើលទារកតែងខិតខំរកទំនុកលួងលោមផ្សេងៗដូចជា ៖

១ - ក្ដាមគ្រោង ក្ដាមស្រវែង មកពីស្រែ ស៊ីពោះនាងអស់. . .

ពេលច្រៀងទំនុក « ក្ដាមគ្រោង ក្ដាមស្រវែង មកពីស្រែ » គេធ្វើម្រាមដៃទាំងរស់រវើមរវាម ដូចជើងក្ដាមវារឲ្យទារកមើល ។ លុះដល់ទំនុក « ស៊ីពោះនាងអស់ » គេយកដៃទៅចាក់ក្រឡេកឲ្យរសើបសើចសប្បាយវិញ ។





២ - តាក់ៗទីងៗ សំឡពងហ៊ីង កង្កែបរាចម៍គោ . . . .។

គេច្រៀងទំនុកនេះជាចង្វាក់ សង្កត់មួយៗ សាទៅសាមក ប្រកបដោយទឹកមុខញញឹម ដើម្បីបង្ហាញឲ្យទារកសប្បាយតាម ។ គេឈប់ច្រៀងបន្តទៀតនៅពេលទារកស្រាយទឹកមុខញញឹមតបវិញ ។

៣ - ខ្លះច្រៀងទំនុកយ៉ាងខ្លីថា « គេលីងបាយសៗ . . . » ប្រកបដោយទឹកមុខក្រមាច់ក្រមើម ហើយចាក់ក្រឡេកទារកទាល់តែស្រាយទឹកមុខសើចសប្បាយវិញដែរ ។

**ខ ~ នៅពេលទារករេះក្រឡាប់ :**

ពេលទារកក្រឡាប់ គេតែងប្រវ៉ៀងលេងឲ្យទារកប្រឹងរើផ្ងារឡើងវិញតាមទំនុកដូចតទៅ ៖

- បួតពែក ភ្នែកមើល ត្រចៀកស្ដាប់ យាយយើងបកឆាប់
  ក្រឡាប់ឆាប់ងើប ឆាប់ងើបៗៗ . . . ។

គេច្រៀងទំនុកនេះជាចង្វាក់ ញាប់ហើយរន្ថើន សាចុះសាឡើងនៅលើពាក្យ « ឆាប់ងើប » ប្រកបដោយទឹកមុខខំប្រឹងរួមទាំងធ្វើសញ្ញាបង្កាប់ឲ្យទារកប្រឹងផ្ងារវិញ ។ ពេលទារកប្រឹងផ្ងារបានរួច គេស្រែហ៊ា « ទីង » ដោយយកដៃទ្រក្បាលកុំឲ្យប៉ះក្ដារ ហើយលួងលោមកុំឲ្យភ័យ ។



គ - នៅពេលទារកបានវ័យប៉ុនគួរសម :

គេប្រវែងលេងដោយអង្គុយលើកៅអី ឬ លើក្តារជើ ហើយឲ្យទារកអង្គុយលើ-កជើង ដែលទប់ដោយចុងម្រាមជើងប្រឹងបះឡើងលើ ។ ឯដៃទាំងពីរកាន់ចុងដៃទារក រួចគេលើកជើងចុះឡើងៗយកយោគជាចង្វាក់មួយៗ ដោយរាយទំនុកផ្សេងៗជាអាទិ៍ដូចតទៅ ៖

១ - កាក់តើក គេលើកបាយស្រាក់ អាចោរឆ្កែណាស៊ីបាយអញអស់ . . . ។

២ - យកយោគ ស្រូវមួយត្រឡោក ក្អែកពាំអស់ . . . . ។ គេច្រៀងតាមទំនុកខាងនេះដែរ តែកាយវិការតាមរបៀបផ្សេង គឺគេដេករាបស្មើ ឯក្បាលជង្គង់បញ្ឈរ ហើយឲ្យទារកអង្គុយលើ-កជើង ។ ឯដៃទាំងពីរកាន់ដៃទារកដែរ រួចបានគេលើកជើងទៅលើហើយដាក់វិញ យោគតាមចង្វាក់មួយៗដូចគ្នា ។







ឃ ‑ នៅពេលទារកចេះកំរើកម្រាមដៃ :

ទារកចេះកំរើកម្រាមដៃចុះឡើងៗ របៀបចង់ចាប់របស់អ្វីមួយ គេត្រូវក្ដាប់លាៗដៃ សាចុះសាឡើង ដើម្បីឲ្យទារកប្រឹងធ្វើតាម ហើយច្រៀងសាចុះសាឡើងនូវចំនុក : « ចាប់ចាប ! ចាប់ចាប ! ឆាងអើយចាប់ចាប ! ៗ ! ៗ ! » ។

ជួនណាទារកកំរើកម្រាមដៃ ហើយបង្វិលកដៃចុះឡើងទៀតមានសភាពដូចចង់រាំ ។ ដើម្បីបង្វឹកឲ្យទំប្រឹងធ្វើកាយវិការនេះឲ្យបានច្រើនផងនោះ គេច្រៀងសាចុះសាឡើងនូវចំនុក : « តាក់ទីងណាយទីងណាយ ! ៗៗ » ។



១ - នៅពេលទារកប្រឹងរៀនដើរឈរ :

ដើម្បីជួយពង្រឹងទឹកចិត្តទារកឲ្យក្លាហាន កុំឲ្យភ័យខ្លាច គេច្រៀងទំនុកថា : « តាក់ទីងទែតៗ នាងអើយទែតៗ » សាចុះសាឡើង ដោយឲ្យសញ្ញាដល់ទារកឲ្យទំប្រឹងដើបឈរផង និងទះដៃជាចង្វាក់ផង ដើម្បីឲ្យទារករំភើបសប្បាយភ្លេចខ្លួនប្រឹងដើបឈរទាល់តែបាន ។





នៅពេលប្រឹងដើបឈរបាន តែនៅមិនទាន់បាននឹងល្អ គឺរេករលចង់តែដាក់គូថអង្គុយនោះ គេនាំគ្នាពង្រឹងចិត្តទារកឲ្យទំប្រឹងទប់ខ្លួនតទៅទៀត ដោយទំនុកថា : « នឹង ! នាងអើយនឹង !ៗ» ប្រកបដោយកាយវិការសង្កត់ក្បាលជាចង្វាក់មួយៗ សាចុះសាឡើង ទាល់តែទារករស់កំលាំង លែងខ្ចីស្តាប់បង្គាប់ធ្វើតាមតទៅទៀត ទើបគេនាំគ្នាឈប់ ហើយនាំទារកសើចបន្លប់ការនឿយហត់ ។



ចម្លាក់កុមារជិះកឪពុក ″រូបនៅ បាយ័ន″

## IV ~ តន្ត្រី និង ជ័យកុមារ

ដូចយើងបានពោលខាងលើ យើងពុំអាចបែងចែកតន្ត្រីពីទំនុកច្រៀងបានទេ ក្នុងន័យនេះ ហើយដែលយើងអាចនឹងចាត់ទុកថា ចម្រៀងក្នុងវ័យកុមារភាពជាតន្ត្រីមួយយ៉ាងសំខាន់ដែរ ។

នៅតាមជនបទស្រុកស្រែចំការ គេតែងឮសំឡេងខ្ទើយៗពីលើចុងឈើ ឬ លើខ្នងគោ ក្របីនៃកុមារគង្វាល ស្រែកច្រៀងលើកចេញជាទំនុកតាមការរំភើបចិត្តរបស់គេជាមួយនឹងធម្មជាតិ ។ សាច់ភ្លេងគឺជាសាច់បទប្រភេទតន្ត្រីមហោរី បាសាក់ យីកេ ប្រពៃណី . . . ។ ជួនកាលគេបេះស្លឹកឈើផ្លុំបំពេ រាំរម្មណ៍គេ និងមិត្តភក្តិគេ ដើម្បីលើកសំរស់ជីវិត ឬ ដើម្បីបំបាត់ពេលវេលាឲ្យកន្លងទៅបានឆាប់រហ័ស ព្រោះការងារឃ្វាលគោក្របី មើលស្រែចំការ គេត្រូវបំពេញចាប់តាំងពីពេលថ្ងៃជិតត្រង់ រហូតដល់ពេលព្រះអាទិត្យជិតអស្តង្គត ។

ក្រៅពីពេលបំពេញការងារផ្សេងៗ ឬ ការសិក្សា កុមារកុមារីខ្មែរទាំងអស់ គេអាចមានពេលសំរាកកំសាន្តសប្បាយជាមួយល្បែងផ្សេងៗជាច្រើន ។ តែយើងខ្ញុំសូមលើកយកតែល្បែងដែលរមដោយទំនុកច្រៀងមានដូចខាងក្រោមនេះ ៖

### ១ ~ ល្បែងបិទមុខ~បិទពួន

ល្បែងនេះគេលេងចាប់ពីបីនាក់ឡើងទៅ ដោយគេឲ្យម្នាក់ចាំកណ្តាលកន្លែងវាលស្រឡះ ដែលគេសន្មតឲ្យឈ្មោះថា « ទី » ដោយបិទភ្នែកមិនឲ្យឃើញអ្នកដទៃទៀតរត់ទៅពួន នៅកន្លែងណាមួយ ។ ការបិទភ្នែកនេះ ជាតំណាមដាច់ខាតរបស់អ្នកចាំទី ។



ប្រសិនបើអ្នកណាលួចមើលគេពួន គេអាចតវ៉ាបានដោយត្រូវឲ្យនៅចាំទីតទៅទៀត ដែលគេហៅថា « ស្ទុយភ្នែក »។ អ្នកដែលរត់ទៅពួន ពេលបានជ្រកនៅកន្លែងណាមួយផ្សេងគ្នាហើយ ហើយយល់ឃើញថាល្មមអាចមិនឲ្យអ្នកចាំទីមើលឃើញអស់គ្នាហើយ ក៏ប្រកាសស្រែកព្រមគ្នាថា « ហើយ ! » ។ អ្នកចាំទីឈរនៅជិតទី ចាំស្រែកហៅឈ្មោះអ្នកនេះអ្នកនោះដែលខ្លួនបានឃើញ ។ តែបើឈរជិតទីមិនឃើញទេ ត្រូវដើររកអ្នកពួនឲ្យឃើញ ។ ពេលឃើញត្រូវញាប់រួចរត់មកជាន់ទី ឬ ដៃកាន់ទីដែលសន្មតនោះឲ្យបានមុនអ្នកពួន ទើបខ្លួនមានសិទ្ធិឲ្យគេចាំទី ហើយអាចទៅពួនវិញម្តង ។ ប៉ុន្តែបើពេលកំពុងរកអ្នកពួនមិនឃើញ ដោយអ្នកពួនរត់មកដល់ទីអស់ អ្នកចាំនោះត្រូវនៅចាំទីរហូត ។ ពួកអ្នកពួនដែលរត់មកដល់ទី ត្រូវស្រែកយ៉ាងខ្លាំងថា « ចូលទី ! » ។

អ្នកដែលត្រូវចាំទីជាដំបូងនោះ ត្រូវយោលទៅតាមទំនុកច្រៀងដែលគេបានអនុវត្ត ដោយឈរជារង្វង់មូល រួចមានអ្នកស្មគ្រចិត្តម្នាក់ស្រែកច្រៀងផង យកដៃទះទ្រូងតិចៗជាចង្វាក់ផង គឺមួយចង្វាក់ទះទៅលើមិត្តភក្តិខ្លួនម្នាក់ថា : « ប៉ិប៉ក់ ស៊ីសំបកមិនចោលគ្រាប់ » ឬតាមទំនុកមួយទៀតថា : « ប៉ិប៉ក់ ឡៅឡាំងស៊ីម៉ាំឃុត* ស៊ីម៉ាំទាំង អ៊ីរេង អ៊ីតង ត្រីរណ្តែងកប់ភ្លក ត្រីផ្ទក់សូត្រមន្ត យកអង្ករចូលបុណ្យ ក្ងានបារាំងជិះឡាន » ។ ពេលចប់ចុងបទនៅលើអ្នកណាម្នាក់ អ្នកនោះជាអ្នកមានសិទ្ធិរត់ពួន តែត្រូវចេញឈររង់ចាំគេអនុវត្តជាបន្តបន្ទាប់តាមចម្រៀង ខាងលើ

* ម៉ាំឃុត –ផ្លែបង្សុត * ភ្លក = ភក់

រហូតទាល់តែនៅសល់តែម្នាក់ចុងក្រោយគេ គឺអ្នកនោះហើយជាអ្នកចាំទីដំបូងគេ ។





២ ‐ ល្បែងបូតសណ្តែក និង ឆះពញាក់

ល្បែងនេះភាគច្រើនគេលេងតែពីរនាក់ទល់មុខគ្នា ឬ បើគេចង់លេងច្រើននាក់ គេត្រូវមានដៃគូរង្គុយទល់មុខគ្នាហើយស្រែកច្រៀងរួមគ្នា ។

ជាដំបូងគេយកបាតដៃបញ្ចូលគ្នា គឺបាតដៃស្តាំផ្ទិបបាតដៃឆ្វេង បាតដៃឆ្វេងផ្ទិបខ្នងដៃស្តាំនៃដៃគូរបស់ខ្លួន ហើយបូតចុះបូតឡើងប្រកបដោយមនោសញ្ចេតនាស្និតស្នាល និង រីករាយ ។ ពេលបូតដៃនោះ គេស្រែកច្រៀងព្រមគ្នាថា : « បូតសណ្តែក រទេះបាក់បែក នាងគីដើរដី រស់ទាំងគេ គេជិះជិះ នាងគីដើរដី ជិះឆ្កែកំជើម ។ ជើមផុត ចង់ស៊ីធំផុត ភ្លើងរលត់ ចង់ស៊ីធំនៅកំពប់មៀវរស់ » ។ ពេលច្រៀងចប់គេទះបាតដៃខ្លួនឯងមួយផ្ទូងទះភ្លៅរៀងៗខ្លួនមួយផ្ទូង រួចទះបាតដៃខ្លួនឯងមួយផ្ទូងទៀត បានលើកដៃស្តាំឈោងខ្វែងទៅទះបាតដៃស្តាំនៃដៃគូរបស់ខ្លួនមួយផ្ទូងទះដៃខ្លួនឯងមួយផ្ទូង រួចលើកដៃឆ្វេងឈោងខ្វែងទៅទះបាតឆ្វេងដៃនៃគូរបស់ខ្លួនមួយផ្ទូង ។ នេះជាមួយវគ្គ ហើយគេចាប់ដំណើរការទះសាថ្មីជាបន្តបន្ទាប់ ដូចដែលយើងខ្ញុំបានរៀបរាប់រួចមកហើយសាចុះសាឡើង តែចង្វាក់ក៏កាន់តែរន្ថើនញាប់ឡើងៗដែរអ្នកណាទន់ដៃវាយលែងទៅរួចអ្នកនោះគេគិតថាចាញ់ ។

របៀបទះដែលយើងខ្ញុំបានរៀបរាប់មកនេះ ជារបៀបមួយបែប តែមានច្រើនបែបទៀត គឺ យោលទៅតាមការសន្មតគ្នា ថាទះភ្លៅប៉ុន្មានដង ទះដៃខ្លួនឯងប៉ុន្មាន រួចទះដៃគូប៉ុន្មាន . . . ។ នៅពេលរន្ថើនចង្វាក់ បើយើងភ្លេច ឬ ច្រឡំ ក៏គេចាត់ទុកថាចាញ់មួយដែរ ។



៣ ‑ ល្បែងលាក់កន្សែង

ល្បែងលាក់កន្សែងគេលេងចាប់ពីប្រាំមួយនាក់ ឬ ប្រាំពីរនាក់ឡើងទៅ ។ ពេលឯកភាពលេងល្បែងនេះហើយ គេវាតវង់



អង្គុយចោងហោងជារង្វង់មូល ដាក់ដៃទាំងពីរនៅមុខ ឬ ប្របខ្លួន និង មានតំណាមដាច់ខាតមិនឲ្យងាកក្រោយ តែគេអាចដៀងភ្នែកលួចមើលបាន ។ គេលេងកណ្ដាលវាលស្រឡះរាបស្មើល្អ ដើម្បីងាយស្រួលរត់ និង មិនបណ្ដាលឲ្យជំពប់ជើងផង ។ បន្ទាប់មកមានអ្នកស្ម័គ្រចិត្តម្នាក់យកក្រមា ឬ ក្រណាត់ផ្សេងៗដែលគេសន្មតហៅថា «កន្សែង» ឆ្នូលកាន់នៅដៃរបៀបបន្លែបន្លំដើររលេះរលាំងយ៉ាងស្វាហាប់ព័ទ្ធជុំវិញពីក្រោយខ្នងអ្នកអង្គុយ ជួនជ្រលបញ្ឆោតធ្វើជាដាក់កន្សែងក្រោយខ្នងអ្នកនេះ ជួនអ្នកនោះ ដើម្បីបន្លំអ្នកមានស្មារតីតិចឲ្យយល់ច្រឡំ ។ ទន្ទឹមគ្នានេះដែរ គេស្រែកច្រៀងទាំងអស់គ្នាបណ្ដើរៗថា : «លាក់កន្សែងឆ្មាខាំកែងអូសលោងៗ . . . » ។ ពេលគេយល់ថា មានអ្នកណាម្នាក់ភ្លេចខ្លួនហើយ គេលួចដាក់កន្សែងក្រោយខ្នងអ្នកនោះ រួចគេដើរព័ទ្ធមួយជុំប្រកបដោយទឹកមុខអាថ៌កំបាំង និង ឲ្យបានរហ័សមកដល់ក្រោយខ្នងអ្នកដែលគេបានដាក់កន្សែង ។ ឱកាសបានមកដល់ក្រោយខ្នងអ្នកនោះ គឺជាជោគជ័យដែលគេប្រាថ្នា ។ គេអរណាស់ គេឆក់យកកន្សែងវាយអ្នកភ្លេចខ្លួននោះ ។ អ្នកភ្លេចខ្លួន កាលបើគេដាក់ទណ្ឌកម្មវាយ ត្រូវស្ទុះរត់មួយជុំរួចមកអង្គុយនៅកន្លែងចាស់វិញបានរួចខ្លួន ហើយគេចាប់ដំណើរការដើរព័ទ្ធជុំវិញដោយស្រែកច្រៀង និង លាក់កន្សែងជាថ្មីតទៅទៀត ។ ប៉ុន្តែជោគជ័យដែលគេប្រាថ្នាច្រើនជិតដល់ពេលបញ្ចប់ត្រូវទទួលបរាជ័យវិញ ព្រោះទឹកមុខស្រ្កិអររបស់គេ អាចបញ្ជាក់ឲ្យអ្នកភ្លេចខ្លួនដែលគេបានដាក់កន្សែងក្រោយខ្នងនោះអាចដឹង គេអាចឆក់រើសកន្សែងទាន់កាន់រត់ដេញវាយអ្នកដាក់វិញ ។ អ្នកដាក់កន្សែងត្រូវរត់មួយជុំរួចមកអង្គុយ

កន្លែងជំនួសអ្នកត្រូវគេដាក់ពីមុនម្តង ។ អ្នកឆក់រើសកន្សែងទាន់នោះ ត្រូវកាន់កន្សែងដើរជុំវិញគេ ហើយស្រែកច្រៀង និង បន្លំដាក់ក្រោយខ្នងគេទាំងអស់ម្តងវិញ ។ គេលេងរបៀបនេះចុះឡើងរហូតដល់ពេលអស់ចិត្តរៀងៗខ្លួន ។





៤ ~ ល្បែងចាក់ទឹកដូង

ល្បែងចាក់ទឹកដូង គឺជាល្បែងសំរាប់លេងបំបាត់ពេលដើម្បីបន្លប់កុមារតូចៗដែលចេះតែយំទារនេះទារនោះ ។ ពិសេសបងៗដែលមើលប្អូន ច្រើនបន្លប់ប្អូនកុំឲ្យយំតាមម្តាយដែលកំពុងបំពេញការងារឬមិននៅផ្ទះ។ ចំពោះមនុស្សចាស់ក៏មានលេងល្បែងប្រភេទនេះដែរ គឺច្រើនលេងក្នុងឱកាសពិធីបុណ្យចូលឆ្នាំខ្មែរ ។

ល្បែងនេះ ជួនកាលលេងតែបងម្នាក់ជាមួយប្អូនតូចម្នាក់ប៉ុណ្ណោះ ។ តែបងៗច្រើននាំប្អូនតូចៗពីរបីនាក់ថែមទៀត ដើម្បីឲ្យមានភាពសប្បាយរីករាយ ។ ជាដំបូង បងធំដែលជាអ្នកនាំផ្តើមលេងនោះ ឲ្យប្អូនតូចៗលាបាតដៃទាំងពីរ ឯបងក៏លាបាតដៃមួយដែរ ដៃម្ខាងទៀតនោះបងក្តាប់ម្រាមប្អូន នៅសល់ម្រាមចង្អុលដៃមួយសំរាប់ទុកចាក់បាតដៃទាំងអស់ដែលលា រួមទាំងបាតដៃរបស់ខ្លួនផង។ ពេលចាក់បាតដៃ បងចាក់បាតដៃតាមចង្វាក់លើបាតដៃម្តងមួយៗ ហើយស្រែកច្រៀងថា < ចាក់ទឹកដូងមីឡុងមីឡា កន្ទុយត្រីប្រាមីឆាងរ៉ុក កន្ទុយត្រីផ្អក់មីឆាងកែវ អកកំបោរប្រចាំវាំង បំពង់ឫស្សីប្រចាំវែក ក្បាលទំពែក ក្អែកជុះរពចម័ដាក់ប៉ក់ លាក់ដៃមួយ > ។ មានខ្លះច្រៀងទំនុកផ្សេងទៀតថា : < ចាក់ទឹកដូងរំពោងរំពាន់ កាច់ឈើឈ្នាន់អន្ទាន់អន្ទង កាច់របងមីឡុងមីឡា កន្ទុយត្រីប្រាមហារុក កន្ទុយត្រីផ្អក់មីឆាងកែវ អកកំបោរប្រចាំវាំង បំពង់ឫស្សីប្រចាំវែក ក្បាលទំពែកក្អែកជុះរពចប័ដាក់ប៉ក់ លាក់ដៃមួយ > ។ កាលបើបទនៃទំនុកនេះចប់ត្រង់ពាក្យ < មួយ > នៅលើបាតដៃអ្នកណា អ្នកនោះត្រូវដកដៃមួយចេញ

យកទៅលាក់ទុកក្រោយខ្នង ។ បងអ្នកចាក់ត្រូវចាក់តទៅទៀត រហូតដល់រសៃដៃដែលត្រូវចាក់ បងក៏នាំប្អូនហៅសើចសប្បាយ ។



គេចាប់ផ្ដើមលេងជាថ្មីទៀត ដើម្បីបន្ថប់ប្អូនដែលយំ ។ ប្រសិនប្អូនយំនោះវានៅតែយំដោយឃ្លាន ឬ ដោយចុញទ្រាន់បងត្រូវឈប់



លេង ហើយនាំប្អូនទៅលេងអ្វីផ្សេងៗទៀត គឺធ្វើយ៉ាងណាឲ្យតែប្អូនសុខចិត្ត ។

៥ ‿ គាច់រាជោម

– កាច់រាជោម ជោមតុយ អ្នកណាជោមស្អុយល្មួយក្អិត កាច់ចង្រិតចូលរន្ធ កាច់រន្ទង់ចូលគូថ ឬ កាច់រន្ទង់ស្រែកញ៉ែក។

ទំនុកខាងលើនេះ មិនសំរាប់លេងគ្រប់ពេលទេ ។ ប៉ុន្តែជាទំនុកគេច្រៀង នៅពេលដែលគេកំពុងតែលេងល្បែងអ្វីមួយជុំគ្នា ហើយមានអ្នកណាជោមស្អុយជះក្លិនមិនល្អរំខានដល់គេ ។ ក្នុងចំណោមអ្នកលេងម្នាក់ៗ អាចដឹងឬសង្ស័យថា អ្នកណាជោមដែរ ប៉ុន្តែគេមិនហ៊ានថាឲ្យចំ ព្រោះវាហាក់ដូចជាជ្រុលពេក ។ ដូច្នេះមានម្នាក់យល់ការហើយក្លាហានហ៊ានចង្អុលមុខ ដោយប្រើសិល្បវិធីក្ដាប់ម្រាមដៃប្អូន ទុកតែម្រាមចង្អុលដៃមួយបញ្ឈរពាក់កណ្ដាលឯចុងកាច់ទេរឲ្យក្រងក់ដូចកង្វេរ លើកដៃដូចពស់បើកពពារ ងាកចុះងាកឡើង ចង្អុលជាចង្វាក់ព្រមទាំងស្រែកច្រៀងនូវទំនុកនេះ ដោយចង្អុលបញ្ចប់ទៅលើអ្នកដែលបានជោម ។

ល្បែងនេះ គឺជាការព្រមាន ដល់អ្នកជោមឲ្យទទួលសារភាព ព្រោះបើមិនចង់ឲ្យគេព្រមាន ចង់ឲ្យគេទទួលស្គាល់ខ្លួនជាមនុស្សល្អ មិនជាអ្នករំខានឲ្យគេហិតក្លិនដ៏សោចរបស់ខ្លួនទេ ខ្លួនអាចស្រែកប្រាប់គេទាំងអស់គ្នាថា « សុំទឹ » ហើយដើរចេញទៅគៀនឆ្ងាយពីគេ ជោមឲ្យក្លិនហើររស់ រួចសឹមមកលេងវិញ ។ មិត្តភក្តិអាចដឹងហើយគេចាត់ទុកជាមនុស្សដឹងខុសត្រូវទៀតផង ។ តែជួនកាលការលេងវាជក់ពេក មានអ្នកខ្លះជ្រុលធ្លាយជោមហួសទៅហើយ

បើចង់កុំឲ្យមិត្តភក្តិខឹង គេត្រូវស្ទុះក្រោករត់ចេញហើយស្រែកថា : « សុំទោស » ទោះជាស្ទុយខ្លះក៏ដោយ ក៏ជាប្រការសម្រន់ការខឹងសម្បារដែរ ។







ចាស់ៗតែងរប់រំថា : ការឲ្យគេហិតជោមនេះជារំពើបាបហើយរពយុខ្លីណាស់ ។

៦ ‑ ល្បែងដាក់លើក្បាល

គេលេងនៅពេលដើរលេង ឬ ពេលចេញពីសាលារៀនទៅផ្ទះ ដោយដើរជាក្រុមៗមានមុខមានក្រោយ ។ ក្នុងចំណោមអ្នកដើរក្រោយ មានអ្នកមានគំនិតខិល ផ្តើមបង្កើតបរិយាកាសឲ្យសប្បាយដោយរើសស្មៅ ឬ ស្លឹកឈើដែលស្រាលលួចយកទៅដាក់លើក្បាលអ្នកណាម្នាក់ដែលដើរមុខ រួចដើរលឿនហួសទៅមុខដោយធ្វើឫកមិនដឹងអ្វីសោះ ។ អ្នកដែលបានគេចូលរួមគំនិតសើចសប្បាយហើយនាំគ្នាស្រែកច្រៀងព្រមគ្នាថា : « ពែកៗដាក់លើក្បាលមិនដឹងខ្លួនៗ » ។ អ្នកដែលត្រូវគេដាក់លើក្បាលខ្លះមិនបានដឹងខ្លួនទេ ព្រោះពេលនោះក៏មានអ្នកជើងខិលម្នាក់ទៀតលួច

ដាក់ទៅលើក្បាលម្នាក់ទៀត ឬ ជួនដាក់លើក្បាលអ្នកខិលទីមួយដែលបានដាក់លើគេហើយនោះផង ។ ហេតុការណ៍នេះបង្កបរិយាកាសឲ្យគេសប្បាយខ្លាំងណាស់ ព្រោះគេសើចហួសចិត្តអ្នកធ្វើរំពើខិលទីមួយ សើចចំអកឲ្យអ្នកត្រូវគេដាក់លើក្បាលទីពីរ ។





អ្នកត្រូវគេដាក់លើក្បាលទីពីរ ក៏ប្រឹងសើចហួសចិត្តដោយមិនដឹងខ្លួនចំពោះអ្នកទីមួយដែរ ។ គេនាំគ្នាស្រែកច្រៀងកាន់តែខ្លាំងឡើងៗហើយទះដៃផង ដែលអាចឲ្យស្មៅ ឬ ស្លឹកឈើធ្លាក់ពីលើក្បាល ទើបអ្នកត្រូវគេដាក់ពីលើក្បាលដឹងខ្លួន ហើយបញ្ចប់ត្រឹមនោះទៅ ឬ ជួនក៏មានបន្តទៅទៀតតាមការដែលគេអាចលួចដាក់ពីលើក្បាលអ្នកណាម្នាក់បាន ដោយបន្តដំណើររហូតដល់ផ្ទះរៀងៗខ្លួន ។

## ៧ ‑ ល្បែងខ្លែងចាប់កូនមាន់

ល្បែងនេះត្រូវមានគ្នាលេងច្រើន ហើយគេចាត់អ្នកដែលមានមាឌធំមាំម្នាក់ឲ្យធ្វើជាមេមាន់ និង ម្នាក់ទៀតធ្វើជាមេខ្លែង ។ ចំពោះអ្នកដែលនៅសល់ធ្វើជាកូនមាន់ មានប៉ុនណាក៏បានដែរឲ្យតែអាចទប់ទល់ ឈរឬរត់គេចទាន់គេបាន ។ ចំពោះសំលៀកបំពាក់មិនមានកំណត់ទេ តែប្រការសំខាន់ត្រូវស្លៀកពាក់ឲ្យជាប់ដើម្បីងាយស្រួលរត់ និង ពេលគេរូញទាញកុំឲ្យគេរូញរបូតបាន ។

ពេលចាត់ចែងស្រុះស្រួលគ្នាហើយ គេត្រូវបង្កាត់ភ្លក់ភ្លើងតូចមួយដោយកំទេចរុស ។ អ្នកដែលធ្វើជាមេមាន់ ហៅអ្នកដែលត្រៀមខ្លួនធ្វើជាកូនមាន់នោះ ឲ្យមកតោងកាន់ចង្កេះតៗគ្នាដោយឈរជាជួររហូតដល់អស់ ។ ជួនកាលមេមាន់ គេបង្គាប់ឲ្យរោបចង្កេះវិញដើម្បីឲ្យមានភាពមាំទាំ និង រើសរកអ្នកខ្លាំងៗហើយ វាងពីរឬបីនាក់ឲ្យនៅចុងកន្ទុយ ដើម្បីទប់ទល់ជាមួយមេខ្លែង ។ បន្ទាប់មកមេមាន់ចាប់ផ្ដើមនាំកូនមាន់ដើរព័ទ្ធជុំវិញភ្លក់ភ្លើង ហើយច្រៀងជៀមដាមចំអកឲ្យមេខ្លែងថា ៖

- ចាប់កូនខ្លែង ប្រលែងកូនរក ពពិចញៀកញ៉ក
  កូនរញេតែមួយ ។
- ជីករន្ធដាំត្រកួន ទន្សាយរត់ពួន ត្រកួនឡើងលាស់។
- ទៀនមួយគូ តាំងយូប៉ាំងព្រះ លើកដៃសំពះ
  ជូនៗសុំភ្លើង . . . . ។

មេខ្លែងឈរស្ដាប់ដោយធ្វើឫកព្រងើយ តែនៅពេលចប់ការច្រៀងរបស់ពួកមាន់ហើយ ក៏ដើរចូលទៅរកភ្នក់ភ្លើង ហើយនិយាយសុំភ្លើងថា : « ជូនៗសុំភ្លើង ! » ។

មេមាន់ឆ្លើយភ្លាមថា : រលត់ ខ្លែងថា : សុំមួយរង្គត់
– : រលាយ – : សុំទឹកបាយ
– : ឆ្កេលិត – : សុំកាំបិត
– : មិនទាន់ច្រុង – : សុំល្ពង
– : មិនទាន់ដាំ – : សុំថ្នាំ
– : មិនទាន់ហាល – : សុំផាល
– : មិនទាន់សិត . . . . ។

ខ្លែងចាញ់ចំណោះ ក៏អង្គុយជិតភ្នក់ភ្លើងនោះទៅ ។ មេមាន់ក៏នាំកូនរបស់ខ្លួនដើរព័ទ្ធជុំវិញភ្នក់ភ្លើងនិងខ្លែង ហើយស្រែកច្រៀងនិងបន្ទរទាំងអស់គ្នាថា :

- ចាប់កូនខ្លែងប្រលែងកូនមាន់ បន្ទរ : រពាំឡយៗ
- បើមេទៅទាន់យកមាន់ទៅលាក់ – : –
- លាក់ឯណា លាក់ក្បាលដំណេក – : –
- រលើកពីដេកវាយមាន់តូងតាង – : –



- បែកចានម៉ៃមួយម៉ៃឲ្យទិញសង ។

មាន់ច្រៀងចប់ នាំគ្នាឈរតំរៀបជាជួរ ហើយខ្លែងស្រែកសុំភ្លើងម្ដងទៀតថា : « ជូនៗសុំភ្លើង » ។ មេមាន់ឆ្លើយថា : « ក្អែកពាំយកទៅទំលាក់ក្នុងទឹកខ្មេរស់ហើយ » រួចហើយគេនាំកូនរបស់គេដើរព័ទ្ធភ្នក់ភ្លើងនិងខ្លែង ហើយស្រែកច្រៀងទៀតថា :

- កំប្រុកតេតតត ឡើងគុម្ពឫស្សី បន្ទរ : រពាំឡយៗ
- កំប្រុកដេកដី ហៅអញធ្វើច្បារ – : –
- កំប្រុករៀបការ ហៅអញស៊ីជំ – : –
- កំប្រុកពោះធំ ហៅអញធ្វើឆ្មប – : –
- កំប្រុកជិតងាប់ ហៅអញយកភ្លើង ។ – : –

ពពួកមាន់ច្រៀងចប់នាំគ្នាឈរស្ងៀម ឯខ្លែងក៏និយាយទទូចសុំភ្លើងមេមាន់ទៀតថា :

ខ្លែង : ជូនៗសុំភ្លើង មេមាន់ : សុំភ្លើងធ្វើអ្វី ?
– : យកទៅដុតខ្យង – : ឲ្យជូនស៊ីផង
– : ស៊ីសំបក . . . . . ។

*(មេមាន់ទឹងមិនឆ្លើយ ឯខ្លែងនិយាយសុំតទៅទៀត ។ )*

ខ្លែង : ឲ្យសុំកូនមុខ មេមាន់ : ឪពុកមិនឲ្យ
– : ឲ្យសុំកូនក្រោយ – : ចាប់បានយកទៅ

ពេលមេមាន់និយាយចប់ភ្លាម ខ្លែងស្ទុះងើបពីភ្នក់ភ្លើងដេញចាប់កូនមាន់ ។ ឯមេមាន់កាងស្លាបប្រឹងការពារកូនមិនឲ្យខ្លែងចាប់បាន ។ ក្នុងការដេញចាប់នេះ លក្ខខណ្ឌនៃការចាប់កូនមាន់ ត្រូវចាប់បេះយកតែកូនក្រោយបង្អស់មុន គឺង ចាប់យកជាបន្តបន្ទាប់

គឺមិនអនុញ្ញាតឲ្យចាប់កូនមុខ ឬ កូនកណ្ដាលមុនទេ ។ ដូច្នេះកូនមាន់ទាំងអស់ ក៏ប្រឹងអោបចង្កេះគ្នាតៗគ្នារត់គេចពេនចុះពេនឡើងតាមមេមិនឲ្យរបេះ ។ ពិសេសកូនមាន់ក្រោយត្រូវប្រុងស្មារតីកុំឲ្យខ្លែងឆាបចាប់យកបាន ។





មេមាន់ឆ្លាតហើយមាំទាំ និង កូនក្រោយ វាងវៃ ខ្លែងមិនងាយចាប់បានទេ មានរយៈពេលយូរណាស់ ។ ប៉ុន្តែខ្លែងមានតែម្នាក់ ឯក្រុមមាន់មានគ្នាច្រើន តែងថ្លឹងចិត្តគ្នាមិនបាន ពេលរត់ត្រូវតែទទឹសទទាស់ដែលជាការផ្ដល់ឱកាសឲ្យខ្លែងឆាបចាប់បាន ម្ដងមួយឬពីររហូតទាល់តែអស់ ។ តែមានលក្ខខណ្ឌមួយទៀត គឺបើកូនមាន់ណាមួយរបូតចេញពីមេដោយការប្រឹងគេច តែចេះក្រាបនឹងដីទាន់នោះ មេខ្លែងមិនត្រូវចាប់ទេ ហើយកូនមាន់នោះ ត្រូវសុំវិវរកឱកាសទៅតោងគ្នាទៀត ។ នៅពេលអស់កូនមាន់ បានសេចក្ដីថាចប់ហើយនោះ គេត្រូវប៉ាវរើសឬយកតាមការស្ម័គ្រចិត្តរកមេមាន់ និង ខ្លែងសាជាថ្មីទៀត ។

គេឈប់លេងនៅពេលហត់ អស់កំលាំងរៀងៗខ្លួន ។

៨ - ទំនុកច្រៀងបំអកកីប្លែងលេង :

- ក្រងោលបោលបាញ់ លាបខ្លាញ់គីង្គក់ ក្រងោលដេកលក់ គីង្គក់លិខ្ទអស់ (ឬគីង្គក់ល្អចថើប) ។

មនុស្សម្នាក់ៗភាគច្រើន សុខ្ចតែបានថែរក្សាសំរិតសំរាងសក់របស់ខ្លួនដោយយកចិត្តទុកដាក់បំផុត តាមកាលនិយម ។ ជាទូទៅ សក់តែងជួយលើកសម្ផស្សមនុស្សគ្រប់រូបឲ្យបានល្អ។ ប្រសិនបើមនុស្សកោរសក់ សម្ផស្សតែងធ្លាក់ចុះ ហើយគួរជាទីចាប់អារម្មណ៍របស់អ្នកដទៃ ។

ដោយមូលហេតុនេះហើយ បានជាកុមារចូលចិត្តច្រៀងទំនុកខាងលើនេះ ចំអកឲ្យមិត្តភក្តិគេណាដែលបានកោរសក់ ទោះជាដោយមូលហេតុមានទុក្ខក៏ដោយ ។



## ៩ - ល្បែងសូកកូឡា-បុងបុង

ល្បែងនេះគេលេងគ្នាច្រើននាក់ជាការល្អ ហើយមិនរើសមាឌតូចធំឡើយ គឺសំរាប់បែងចែកគ្នាទាញយកឈ្នះចាញ់នៅពេលសំរាប់ចេញជាលទ្ធផល ។ ន័យនេះបានសេចក្ដីថា ជាដំបូងមានកុមារមាឌធំៗពីរនាក់ជាអ្នកនាំរពាទ៏ ដោយលើកដៃប្រជាងខ្ពស់កាន់ភ្ជាប់គ្នា ហើយគេសន្មតរៀងៗខ្លួនថា អ្នកណាជាអ្នកយកឈ្មោះសូកកូឡា និង ម្នាក់ទៀតយកឈ្មោះបុងបុង ។ អ្នកនៅសល់ទាំងប៉ុន្មានត្រូវឈរតោងកន្ទុយគ្នា ហើយដើររុលចូលក្រោមដៃអ្នកទាំងពីរ ដោយស្រែកច្រៀងជាបណ្ដើរៗថា : « សូកកូឡា-បុងបុងៗៗ . . . » ។ នៅពេលអ្នកទាំងពីរ គឺអ្នកលើកដៃប្រជាងខ្ពស់ឯកភាពគ្នាទំលាក់ដៃចុះ ស្ទាក់មិនឲ្យរុលក្រោមដៃគេ គេទាំងពីរត្រូវសួរថា : « សូកកូឡា-បុងបុង ? » បានសេចក្ដីថាតើយកសូកកូឡា ឬ យកបុងបុង ? ។ បើអ្នកគេត្រូវស្ទាក់ស្រែកថា សូកកូឡា អ្នកនោះត្រូវទៅឈរផ្នែកខាងសូកកូឡា តែបើស្រែកថាបុងបុង ត្រូវទៅឈរផ្នែកខាងបុងបុង ។ ប៉ុន្តែនៅពេលបញ្ជាក់ការស្ទាក់ដើម្បីសួរមនុស្សបានម្នាក់ៗហើយ អ្នកទាំងពីរនោះតែងខ្សឹបគ្នាសន្មតដូរឈ្មោះ ឬ ក៏មិនដូរដោយទុកដដែល តែមិនឲ្យអ្នកដើររុលក្រោយដៃខ្លួនដឹងទេ ។ គេស្ទាក់និងសួររបៀបនេះ លុះត្រាតែរស់អ្នកតោងកន្ទុយ ។ បន្ទាប់មកបានគេប្រមូលបក្សពួកគេរៀងៗខ្លួន ដើម្បីប្រទាញយកឈ្នះចាញ់រហូតដល់ដួលរកេតរកូត ។ ពួកដែលចាញ់គេ គឺពួកដែលគេបានរូសទាញយករស់មនុស្សពីពួកខាងខ្លួន ។

ចាស់ៗបានដំណាលថា : ល្បែងនេះកើតឡើងដោយសារ

ហានបនុស្សពីរនាក់ក្តីងណ្តើមដីថ្លីគ្នា ។ ម្នាក់ៗខំប្រមែលប្រមូលកៀរគរគ្នា ដើម្បីឲ្យបានសំលេងច្រើនតែរៀងៗខ្លួន ។ ប៉ុន្តែនៅទីបញ្ចប់ អ្នកដែលដួលនោះគឺអ្នកក្តី និង អ្នកតូចតាច ឯអ្នកមានកំឡាំងនៅតែឈរបានរឹងមាំ ព្រោះដូចពាក្យស្លូកក្លូឡា គឺស្លូកក្រឡាបញ្ញីឬបងៗ ព្រោះពាក្យបុងបុង គឺបងៗដែលមានតួនាទីធំ ។

